ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ១៩៨ MIH / 2016

# ប្រកាស
# ស្តីពី
# នីតិវិធី និងបែបបទស្នើសុំបង្កើតរោងចក្រ និងសិប្បកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

## ជំពូកទី១
## លក្ខខណ្ឌដំបូង

### ប្រការ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់អំពីនីតិវិធី បែបបទ ក្នុងការស្នើសុំប្រកាសបង្កើត និងការចុះបញ្ជីរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)
ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៥៤
អ៊ីមែល: mih.smcabinet@gmail.com

**ប្រការ២.- គោលដៅ**

ប្រកាសនេះមានគោលដៅ ដូចខាងក្រោម ៖

១- ការពារសុខុមាលភាពសាធារណៈ ដោយធានាថា រូបវន្តបុគ្គល និងនីតិបុគ្គល ដែលបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម នៅក្នុងប្រទេសកម្ពុជា ត្រូវអនុលោមតាមច្បាប់

២- ផ្តល់គោលការណ៍ណែនាំច្បាស់លាស់ដល់មន្ត្រីរាជការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីរបៀបអនុវត្តភារកិច្ចរបស់ខ្លួនក្នុងការអនុញ្ញាតបង្កើត និងចុះបញ្ជីរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ស្របតាមច្បាប់

៣- ជំរុញការបង្កើតឲ្យបានឆាប់រហ័សនូវរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មថ្មីៗ ដែលមានការទទួលខុសត្រូវនៅក្នុងប្រទេសកម្ពុជាតាមរយៈ ៖

ក- ការផ្តល់គោលការណ៍ណែនាំ និងបទដ្ឋានច្បាស់លាស់ស្តីពីរបៀបការអនុញ្ញាតបង្កើត និងចុះបញ្ជីរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ស្របតាមច្បាប់

ខ- ការកំណត់នីតិវិធីច្បាស់លាស់ សម្រាប់ការស្នើសុំប្រកាសអនុញ្ញាតថ្នាក់ជាតិ ដល់ការបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដែលច្បាប់តម្រូវឲ្យមានការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ព្រមជាមួយការធ្វើការសម្របសម្រួល និងជំរុញសកម្មភាពរបស់អង្គភាព ឬទីភ្នាក់ងារផ្សេងទៀត ដែលពាក់ព័ន្ធនឹងការចេញប្រកាសអនុញ្ញាតឲ្យបានឆាប់រហ័ស មានគណនេយ្យភាព និងតម្លាភាព

គ- ការផ្តល់នូវប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ជាលក្ខណៈអចិន្ត្រៃយ៍ស្របតាមច្បាប់ ប្រសិនបើម្ចាស់រោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម គោរពតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិជាធរមានផ្សេងទៀត រួមទាំងប្រកាសស្តីពីបញ្ញត្តិកម្មលើកិច្ចដំណើរការ ឬបទប្បញ្ញត្តិផ្សេងទៀត ដែលតម្រូវឲ្យធ្វើការទូទាត់កម្រៃសេវាសាធារណៈលើសេវាបញ្ញត្តិកម្មផ្សេងៗ

ឃ- ការសម្របសម្រួលលក្ខខណ្ឌតម្រូវនៃប្រកាសនេះ ជាមួយលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិ ដែលអនុវត្តដោយក្រសួង ឬស្ថាប័នផ្សេងៗ ដើម្បីចៀសវាងភាពផ្ទុយគ្នា ឬការបង្កើតឲ្យមានបញ្ញត្តិកម្មត្រួតគ្នា។

៤- លើកទឹកចិត្តដល់ការបង្កើតសហគ្រាសកម្មន្តសាល ដែលមានស្តង់ដារប្រតិបត្តិការ និងគុណភាពទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ដោយផ្តល់នូវយន្តការ និងដំណើរការស្ម័គ្រចិត្ត ដើម្បីទទួលបាននូវការបញ្ជាក់ថាជាសហគ្រាសកម្មន្តសាលស្តង់ដារខ្ពស់ឆ្លើយតបបានតាមបទដ្ឋានសុវត្ថិភាព និងគុណភាពផលិតផល ដែលមានការទទួលស្គាល់ជាអន្តរជាតិ។

**ប្រការ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសហគ្រាសកម្មន្តសាល ដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៤.- និយមន័យ**

សហគ្រាសកម្មន្តសាល ៖ សំដៅដល់រោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដែលមានការអនុញ្ញាតឲ្យបង្កើត ឬចុះបញ្ជីស្របតាមច្បាប់ នៅក្រោមលក្ខខណ្ឌតម្រូវ នៃប្រកាសនេះ។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ( ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៩៩
អ៊ីម៉ែល: mih.smcabinet@gmail.com

រោងចក្រ ៖ សំដៅដល់សហគ្រាសកម្មន្តសាល ដែលមាន ឬរំពឹងថា នឹងមានឧបករណ៍ ម៉ាស៊ីន សម្ភារ និងបរិក្ខារ ដែលត្រូវប្រើនៅក្នុងសហគ្រាស ដើម្បីផលិតផលិតផល ដែលមានទុនសមមូលសរុបច្រើនជាង ៥០០.០០០ (ប្រាំរយពាន់)ដុល្លារអាមេរិក។

សហគ្រាសធុនមធ្យម ៖ សំដៅដល់សហគ្រាសកម្មន្តសាល ដែលមាន ឬរំពឹងថា នឹងមានឧបករណ៍ ម៉ាស៊ីន និងបរិក្ខារ ដែលត្រូវប្រើនៅក្នុងសហគ្រាស ដើម្បីផលិតផលិតផល ដែលមានទុនសមមូលសរុបចន្លោះពី ២៥០.០០០ (ពីររយហាសិបពាន់) ទៅ ៥០០.០០០ (ប្រាំរយពាន់)ដុល្លារអាមេរិក។

សហគ្រាសធុនតូច ៖ សំដៅដល់សហគ្រាសកម្មន្តសាល ដែលមាន ឬរំពឹងថា នឹងមានឧបករណ៍ ម៉ាស៊ីន និងបរិក្ខារ ដែលត្រូវប្រើនៅក្នុងសហគ្រាស ដើម្បីផលិតផលិតផល ដែលមានទុនសមមូលសរុបចន្លោះពី ៥០.០០០ (ហាសិបពាន់) ទៅក្រោម ២៥០.០០០ (ពីររយហាសិបពាន់)ដុល្លារអាមេរិក។

សិប្បកម្ម ៖ សំដៅដល់សហគ្រាសកម្មន្តសាល ដែលមាន ឬរំពឹងថា នឹងមានឧបករណ៍ ម៉ាស៊ីន និងបរិក្ខារ ដែលត្រូវប្រើនៅក្នុងសហគ្រាស ដើម្បីផលិតផលិតផល ដែលមានទុនសមមូលសរុបតិចជាង ៥០.០០០ (ហាសិបពាន់) ដុល្លារអាមេរិក។

ឯកសារតម្រូវ ៖ សំដៅដល់ឯកសារ ដែលអ្នកស្នើសុំប្រកាសបង្កើត ឬចុះបញ្ជីរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មទាំងអស់ ត្រូវផ្តល់ឯកសារតាមការតម្រូវនៃប្រកាសនេះ។

ពាក្យសុំប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ៖ សំដៅដល់សំណើផ្លូវការជាលាយលក្ខណ៍អក្សរ ដែលបានបញ្ជូនមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីចេញការអនុញ្ញាតឲ្យបង្កើតសហគ្រាសកម្មន្តសាលមួយយោងតាមលក្ខខណ្ឌតម្រូវនៃប្រកាសនេះ ដែលរួមមានពាក្យស្នើសុំរួម និងឯកសារបែបបទចាំបាច់ទាំងអស់ មានចែងសម្រាប់ប្រភេទនៃប្រកាសអនុញ្ញាត។

ប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ៖ សំដៅដល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរមានសុពលភាពអចិន្ត្រៃយ៍ ដែលផ្តល់ឲ្យអ្នកស្នើសុំដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដែលតម្រូវឲ្យសុំច្បាប់ រួមទាំងលក្ខខណ្ឌលម្អិតនានាដែលចែងក្នុងប្រកាសអនុញ្ញាតនោះ។ ក្រោយការបញ្ចប់ការសាងសង់រួចរាល់ហើយ រោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ត្រូវមានវិញ្ញាបនបត្រអនុញ្ញាតដំណើរការមួយទៀតមុនចាប់ផ្តើមដំណើរការដំបូង។

ពាក្យសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការ ៖ សំដៅដល់សេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ពីអ្នកស្នើសុំបញ្ជាក់ថា សហគ្រាសកម្មន្តសាលរបស់ខ្លួន ដែលមានប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មនោះ ត្រូវបានសាងសង់រួចរាល់ និងមានលក្ខណៈគ្រប់គ្រាន់ អាចចាប់ផ្តើមដំណើរការអនុលោមតាមបទដ្ឋានបច្ចេកទេសកំណត់ដោយក្រសួង ស្របតាមលក្ខខណ្ឌនៃប្រកាសបង្កើត ហើយស្នើសុំក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចេញនូវវិញ្ញាបនបត្រអនុញ្ញាតដំណើរការ។ ចំពោះរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដែលតម្រូវឲ្យស្នើសុំចុះបញ្ជី ពាក្យស្នើសុំចុះបញ្ជី គឺជាពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការជាមួយគ្នា ដោយពុំចាំបាច់មានការធ្វើពាក្យស្នើសុំដោយឡែកបន្ថែមទៀតទេ។

វិញ្ញាបនបត្រអនុញ្ញាតដំណើរការ ៖ សំដៅដល់ការទទួលស្គាល់ជាលាយលក្ខណ៍អក្សរពីក្រសួង ឬមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ដែលបញ្ជាក់ថា រោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម បានសាងសង់ត្រឹមត្រូវ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៥៤
អ៊ីម៉ែល: mih.smcabinet@gmail.com

រួចរាល់ និងមានលក្ខណៈសម្បត្តិស្របតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម។

វិញ្ញាបនបត្រអនុញ្ញាតដំណើរការ គឺជាឯកសារមាន១(មួយ)ទំព័រក្នុងទម្រង់ ដែលកំណត់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលមានព័ត៌មានមួយចំនួនដូចជា ៖ ឈ្មោះម្ចាស់សហគ្រាសកម្មន្តសាល អាសយដ្ឋានទំនាក់ទំនង និងទីតាំងរបស់សហគ្រាសកម្មន្តសាល ប្រភេទទំនិញដែលផលិតនៅក្នុងសហគ្រាស លេខសម្គាល់អចិន្ត្រៃយ៍របស់សហគ្រាសកម្មន្តសាល កាលបរិច្ឆេទចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការ និងកាលបរិច្ឆេទផុតកំណត់នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការ។

លក្ខខណ្ឌតម្រូវនៃប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ៖ សំដៅដល់បទដ្ឋានបច្ចេកទេសអប្បបរមាតម្រូវឱ្យមានភាពអនុលោមដែលកំណត់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីទទួលបានការអនុញ្ញាតណាមួយយោងតាមប្រកាសនេះ។

ពាក្យស្នើសុំចុះបញ្ជី ៖ សំដៅដល់ការជូនដំណឹងផ្លូវការដល់មន្ទីរ ឬក្រសួងឧស្សាហកម្ម និងសិប្បកម្ម អំពីការបង្កើត និងចាប់ផ្ដើមដំណើរការរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដែលពុំមែនជាប្រភេទរោងចក្រ សហគ្រាស ដូចមានចែងក្នុងមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ការចុះបញ្ជី ៖ សំដៅដល់ការចុះបញ្ជីរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ត្រូវចាត់ទុកបានបំពេញចប់សព្វគ្រប់មានលក្ខណៈពេញលេញ នៅពេលដែលក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឬមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត បានចុះបញ្ជីកត់ត្រាទទួលពាក្យស្នើសុំចុះបញ្ជី បានចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការ និងផ្ដល់លេខសម្គាល់សម្រាប់យោងអចិន្ត្រៃយ៍។

អ្នកស្នើសុំ ៖ សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលចុះហត្ថលេខា លើលិខិតស្នើសុំអនុលោមតាមប្រកាសនេះ។ អ្នកស្នើសុំមានសិទ្ធិឱ្យភ្នាក់ងារជាភាគីទីបី ធ្វើជាតំណាងរបស់ខ្លួន ដើម្បីរៀបចំឯកសារ និងដំណើរការដាក់ពាក្យស្នើសុំ។

លិខិតស្នើសុំ ៖ សំដៅដល់ទំព័រដំបូងនៃពាក្យស្នើសុំប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ពាក្យសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការ ឬពាក្យស្នើសុំចុះបញ្ជីក្នុងទម្រង់ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ "ក" នៃប្រកាសនេះ។

រោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម តម្រូវស្នើសុំចុះបញ្ជី ៖ សំដៅដល់សហគ្រាសកម្មន្តសាលទាំងអស់ ដែលស្ថិតនៅក្រោមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ដូចមានចែងក្នុងមាត្រា២០ និងមាត្រា២៣។

សិប្បកម្មតម្រូវឱ្យសុំប្រកាសបង្កើត ៖ សំដៅដល់ប្រភេទសិប្បកម្ម ដែលផលិតម្ហូបអាហារ ឬភេសជ្ជៈសម្រាប់មនុស្សទទួលទាន ផលិតសារធាតុគីមី ឬផលិតសារធាតុមានគ្រោះថ្នាក់ផ្សេងទៀត ត្រូវធ្វើការស្នើសុំប្រកាសបង្កើត និងវិញ្ញាបនបត្រអនុញ្ញាតដំណើរការ ជាមុនពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម មុនការបង្កើត ឬការចាប់ផ្ដើមដំណើរការ។

សហគ្រាសកម្មន្តសាលមានបទដ្ឋានបច្ចេកទេសខ្ពស់ ៖ សំដៅដល់រោងចក្រ ឬសហគ្រាសសិប្បកម្មតម្រូវសុំប្រកាសបង្កើត ដែលបានជ្រើសរើសដោយស្ម័គ្រចិត្ត ស្នើសុំទទួលការបញ្ជាក់ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៥៤
អ៊ីមែល: mih.smcabinet@gmail.com

បន្ថែមថា ជាសហគ្រាសបំពេញបាននូវភាពអនុលោមតាមបទដ្ឋានសុវត្ថិភាព និងគុណភាពផលិត ដែលមានការទទួលស្គាល់ជាអន្តរជាតិ។

**លេខសម្គាល់អចិន្ត្រៃយ៍** ៖ សំដៅដល់សហគ្រាសកម្មន្តសាលទាំងអស់ ដែលទទួលបានវិញ្ញាបនបត្រអនុញ្ញាតដំណើរការដំបូងរបស់ខ្លួនស្របតាមប្រកាសនេះ នឹងត្រូវទទួលបានក្នុងពេលជាមួយគ្នានោះនូវលេខសម្គាល់សម្រាប់យោងអចិន្ត្រៃយ៍តែមួយគត់សម្រាប់សហគ្រាស ដើម្បីប្រើជាអត្តសញ្ញាណយោង ងាយស្រួលក្នុងការគ្រប់គ្រងទិន្នន័យ និងស្ថិតិ។

## ផ្នែកទី២
## ដំណើរការដាក់ពាក្យសុំ និងលក្ខខណ្ឌទូទៅ

### ប្រការ៥.- ដំណើរការដាក់ពាក្យសុំប្រកាសបង្កើត និងចុះបញ្ជី

១- មុនពេលរូបវន្តបុគ្គល ឬនីតិបុគ្គលបង្កើត និងចាប់ផ្តើមដំណើរការរោងចក្រថ្មី បុគ្គលនោះ ឬភ្នាក់ងាររបស់ខ្លួន ត្រូវអនុវត្តកាតព្វកិច្ចដូចតទៅ ៖

- បានដាក់ពាក្យស្នើសុំប្រកាសបង្កើតរោងចក្រត្រឹមត្រូវ
- បានបង់កម្រៃសេវាទទួលពាក្យសុំ
- បានទទួលប្រកាសបង្កើតរោងចក្រ
- បានដំណើរការសាងសង់រោងចក្រតាមគម្រោងស្នើសុំ និង
- បានទទួលវិញ្ញាបនបត្រអនុញ្ញាតដំណើរការ។

២- មុនពេលរូបវន្តបុគ្គល ឬនីតិបុគ្គលបង្កើត និងចាប់ផ្តើមដំណើរការសិប្បកម្ម តម្រូវឲ្យសុំប្រកាសបង្កើតស្របតាមប្រកាសនេះ បុគ្គលនោះ ឬភ្នាក់ងាររបស់ខ្លួន ត្រូវអនុវត្តកាតព្វកិច្ចដូចតទៅ ៖

- បានដាក់ពាក្យស្នើសុំប្រកាសបង្កើតសិប្បកម្មត្រឹមត្រូវ
- បានបង់កម្រៃសេវាទទួលពាក្យសុំ
- បានទទួលប្រកាសបង្កើតសិប្បកម្ម និង
- បានទទួលវិញ្ញាបនបត្រអនុញ្ញាតដំណើរការ។

៣- មុនពេលរូបវន្តបុគ្គល ឬនីតិបុគ្គល បង្កើត និងចាប់ផ្តើមដំណើរការសិប្បកម្ម តម្រូវស្នើសុំចុះបញ្ជីអនុលោមតាមប្រកាសនេះ បុគ្គលនោះ ឬភ្នាក់ងាររបស់ខ្លួន ត្រូវអនុវត្តកាតព្វកិច្ចដូចតទៅ ៖

- បានដាក់ពាក្យសុំចុះបញ្ជីត្រឹមត្រូវ
- បានបង់កម្រៃសេវាចុះបញ្ជី និង
- បានទទួលវិញ្ញាបនបត្រចុះបញ្ជី និង/ឬវិញ្ញាបនបត្រអនុញ្ញាតដំណើរការ។

៤- ពាក្យស្នើសុំនីមួយៗ ត្រូវបំពេញត្រឹមត្រូវតាមគំរូពាក្យស្នើសុំ និងឯកសារតម្រូវសម្រាប់ប្រភេទជាក់លាក់នៃពាក្យស្នើសុំនោះ។

៥- ការទទួលពាក្យស្នើសុំ នឹងត្រូវធ្វើបន្ទាប់ពីពាក្យស្នើសុំ ត្រូវបានពិនិត្យផ្ទៀងផ្ទាត់លើភាពអនុលោមជាមួយលក្ខខណ្ឌនានា និងសេចក្តីណែនាំចែងក្នុងប្រកាសនេះ បានត្រឹមត្រូវរួចហើយ។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com

៦- ពាក្យស្នើសុំ ដែលបំពេញបានត្រឹមត្រូវទាំងអស់ នឹងត្រូវទទួលយកដើម្បីពិនិត្យ និងសម្រេច។ ក្រោយពេលពាក្យស្នើសុំ ត្រូវបានទទួលយកភ្លាម អ្នកស្នើសុំត្រូវបង់កម្រៃសេវាដែលបានកំណត់។

៧- វិញ្ញាបនបត្រចុះបញ្ជី ឬ/និងវិញ្ញាបនបត្រអនុញ្ញាតដំណើរការ នឹងត្រូវផ្តល់ជូនដោយមន្ទីរឧស្សាហកម្ម និងសិប្បកម្មក្នុងរយៈពេលយ៉ាងយូរ ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពេលបានទទួលពាក្យស្នើសុំ។

៨- ប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម នឹងត្រូវផ្តល់ជូនអ្នកស្នើសុំ ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេលយ៉ាងយូរ ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ នៅក្រោយពេលពាក្យស្នើសុំត្រូវបានផ្ទៀងផ្ទាត់ត្រឹមត្រូវ និងទទួលយកដើម្បីធ្វើការពិនិត្យ និងវាយតម្លៃ ដោយអង្គភាពជំនាញរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ដើម្បីទទួលបានប្រកាសបង្កើត អ្នកស្នើសុំត្រូវផ្តល់ព័ត៌មាន និងឯកសារតម្រូវចាំបាច់នានា ស្តីពីសហគ្រាសកម្មន្តសាល ដែលអ្នកស្នើសុំមានបំណងដំណើរការ។

៩- លក្ខខណ្ឌតម្រូវនៃប្រកាសបង្កើត និងចុះបញ្ជីចែងក្នុងប្រកាសនេះ មិនអនុវត្តចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលធ្វើសកម្មភាពនានា ហើយដែលមិនស្ថិតក្រោមបទប្បញ្ញត្តិនៃប្រកាសនេះ។

**ប្រការ៦.- ពាក្យស្នើសុំ**

ពាក្យស្នើសុំ អាចទំនាក់ទំនងរកបាននៅអាសយដ្ឋាន ដូចខាងក្រោម ៖

១- មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត

២- ច្រកចេញ-ចូលតែមួយនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឬ

៣- គេហទំព័ររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម www.mih.gov.kh

**ប្រការ៧.- ទីកន្លែង និងពេលវេលាដាក់ពាក្យស្នើសុំ**

ពាក្យស្នើសុំចុះបញ្ជី និងវិញ្ញាបនបត្រអនុញ្ញាតដំណើរការសិប្បកម្ម ត្រូវដាក់នៅមន្ទីរឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងរាជធានី ខេត្ត ដែលសិប្បកម្មនោះ ត្រូវបោះទីតាំង។ ពាក្យស្នើសុំប្រកាសបង្កើត និងវិញ្ញាបនបត្រដំណើរការរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ត្រូវដាក់ និងទទួល ដើម្បីពិនិត្យ នៅច្រកចេញ-ចូលតែមួយនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឬនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ក្នុងរាជធានី ខេត្ត ដែលរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដែលខ្លួនបោះទីតាំង។

ប្រសិនបើពាក្យស្នើសុំប្រកាសបង្កើត ត្រូវបានដាក់នៅមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត ឬការិយាល័យពាក់ព័ន្ធផ្សេងទៀត មន្ទីរ ឬការិយាល័យនោះ ត្រូវបញ្ជូនច្បាប់ដើមភ្លាមៗមកកាន់ច្រកចេញ-ចូលតែមួយនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រោយបានទទួលពាក្យស្នើសុំ និងបានថតចម្លងឯកសារពាក់ព័ន្ធសម្រាប់ការងារចាំបាច់របស់ខ្លួនរួចហើយ។

ការទទួលពាក្យស្នើសុំ ត្រូវធ្វើនៅរៀងរាល់ពេលម៉ោងធ្វើការ។ ពាក្យស្នើសុំចុះបញ្ជី ត្រូវដាក់ស្នើសុំក្នុងរយៈពេលយ៉ាងយូរ ៧(ប្រាំពីរ)ថ្ងៃ ក្រោយពេលអ្នកស្នើសុំបានចាប់ផ្តើមដំណើរការសិប្បកម្ម តម្រូវស្នើសុំធ្វើការចុះបញ្ជី។

**ប្រការ៨.- សេចក្តីសម្រេចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

ក្រោយពេលពាក្យស្នើសុំត្រូវបានទទួលយកដើម្បីធ្វើការពិនិត្យ និងសម្រេច ក្រសួងឧស្សាហកម្ម និងសិប្បកម្មនឹងផ្តល់សេចក្តីសម្រេចឆ្លើយតបនឹងសំណើសុំប្រកាសអនុញ្ញាតនានា តាមរូបភាពណាមួយ ដូចតទៅ ៖

១- ផ្តល់ការឯកភាពយល់ព្រម និងផ្តល់ប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មដោយគ្មានលក្ខខណ្ឌ។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com

២- ផ្តល់ការឯកភាពយល់ព្រម និងផ្តល់ប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ព្រមជាមួយនឹងលក្ខខណ្ឌ ដោយតម្រូវឲ្យអ្នកស្នើសុំផ្តល់បន្ថែមនូវឯកសារ ដូចខាងក្រោម ៖

ក- លិខិតអនុញ្ញាតបើកទីតាំងពីរដ្ឋបាលមូលដ្ឋាន និង/ឬការសាងសង់ ឬលិខិតអង្កេតសុវិធាន-អសុវិធាន (កម្រិតឃុំ/សង្កាត់) សម្រាប់សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម

ខ- លិខិតឯកភាពពីក្រសួងបរិស្ថានសម្រាប់របាយការណ៍វាយតម្លៃ និងផែនការការពារផលប៉ះពាល់បរិស្ថាន

គ- លិខិតបញ្ជាក់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអាជ្ញាធររាជធានី ខេត្ត មានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត។

៣- ស្នើឲ្យបំភ្លឺបន្ថែម ឬតម្រូវឲ្យអ្នកស្នើសុំធ្វើការកែលម្អបំពេញបន្ថែម ឬការកែប្រែពាក្យសុំ។

៤- ធ្វើការបដិសេធចំពោះពាក្យស្នើសុំ។ ប្រសិនបើក្រសួងឧស្សាហកម្ម និងសិប្បកម្ម សម្រេចឆ្លើយតបតាមរូបភាពណាមួយខាងលើផ្សេងពីការផ្តល់ប្រកាសបង្កើតដោយគ្មានលក្ខខណ្ឌ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងធ្វើការពន្យល់ជាលាយលក្ខណ៍អក្សរឲ្យបានច្បាស់លាស់អំពីហេតុផលនៃការសម្រេចចិត្តនេះ។ នៅក្នុងករណីទី២ និងទី៣ ខាងលើ ក្រសួងត្រូវផ្តល់សេចក្តីណែនាំលម្អិតគ្រប់គ្រាន់ ដើម្បីឲ្យអ្នកស្នើសុំបន្តការស្នើសុំរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

## ប្រការ៩.- ការពិនិត្យ ការកំណត់ប្រភេទ និងការកែពាក្យស្នើសុំ

មន្ត្រីដែលទទួលបន្ទុកទទួលពាក្យស្នើសុំនឹងធ្វើការពិនិត្យមើលឡើងវិញលើពាក្យសុំនីមួយៗ (រួមទាំងឯកសារចាំបាច់សម្រាប់ពាក្យសុំ) ដើម្បីផ្ទៀងផ្ទាត់ភាពពេញលេញ និងត្រឹមត្រូវមុនពេលពាក្យសុំត្រូវបានទទួលយក និងធ្វើការចុះលេខចូលនៃការទទួលពាក្យ។ នៅពេលធ្វើការផ្ទៀងផ្ទាត់ភាពពេញលេញ មន្ត្រីទទួលពាក្យមិនត្រូវពិនិត្យវិនិច្ឆ័យលើគុណសម្បត្តិនៃពាក្យស្នើសុំឡើយ ប៉ុន្តែត្រូវទទួលយកពាក្យសុំទាំងអស់ ដែលគោរពបានពេញលេញតាមបទដ្ឋានអប្បបរមាសម្រាប់ការដាក់ពាក្យស្នើសុំដែលពាក់ព័ន្ធនោះ។ ការពិនិត្យវាយតម្លៃលើគុណសម្បត្តិនៃពាក្យសុំ ត្រូវធ្វើឡើងតែនៅក្រោយពេលពាក្យស្នើសុំ ត្រូវបានទទួលយករួចហើយដោយមន្ត្រីទទួលពាក្យប៉ុណ្ណោះ។

ពាក្យស្នើសុំចុះបញ្ជី នឹងពុំត្រូវយកមកពិនិត្យវាយតម្លៃលើគុណសម្បត្តិនៃសិប្បកម្មស្នើសុំឡើយ។ ប៉ុន្តែមន្ត្រីដែលទទួលពាក្យស្នើសុំ ត្រូវបញ្ជាក់ដោយផ្អែកលើឯកសារពាក្យសុំថា តើសិប្បកម្មដែលសុំចុះបញ្ជី ពិតជាប្រភេទសិប្បកម្ម តម្រូវស្នើសុំចុះបញ្ជី ឬ ៖

១- មិនអាចចុះបញ្ជីដោយសារសិប្បកម្មផលិតផលិតផលដែលស្ថិតក្នុងបញ្ជីផលិតផល ឬសិប្បកម្មតម្រូវឲ្យសុំប្រកាសអនុញ្ញាតបង្កើត ឬ

២- សិប្បកម្មមានទំហំធំពេកមិនអាចចាត់ទុកថា ជាសិប្បកម្មតម្រូវឲ្យស្នើសុំចុះបញ្ជី ប៉ុន្តែត្រូវស្នើសុំប្រកាសបង្កើតជាប្រភេទរោងចក្រ សហគ្រាសធុនតូចនិងមធ្យមវិញ។

ករណីពាក្យសុំណាមួយ ត្រូវបានបដិសេធ មន្ត្រីទទួលពាក្យនោះ ត្រូវផ្តល់ដល់អ្នកស្នើសុំភ្លាមៗនូវហេតុផលជាក់លាក់អំពីការបដិសេធ និងយោបល់ណែនាំអំពីការកែតម្រូវ ដើម្បីឲ្យពាក្យសុំត្រូវបានទទួលយក ដើម្បីពិនិត្យ និងសម្រេច។ អ្នកស្នើសុំទាំងអស់ អាចទំនាក់ទំនងនៅការិយាល័យច្រកចេញ-ចូលតែមួយនៃក្រសួងឧស្សាហកម្ម និងសិប្បកម្មក្នុងម៉ោងធ្វើការ ដើម្បីស្នើសុំការពន្យល់ ឬការបំភ្លឺទាក់ទងនឹងការបំពេញពាក្យសុំដោយឥតគិតថ្លៃ ឬដើម្បីធ្វើសារទុក្ខស្នើសុំជំនួយអន្តរាគមន៍ជាមួយមន្ត្រីទទួលពាក្យ ដែលអ្នកស្នើសុំជឿជាក់ថា បានបដិសេធទទួលពាក្យស្នើសុំដោយមិនត្រឹមត្រូវ។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ( ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៥៤
អ៊ីម៉ែល: mih.smcabinet@gmail.com

## ប្រការ១០.- ឯកសារចាំបាច់

មុនពេលពាក្យស្នើសុំ ត្រូវបានទទួលយកដើម្បីពិនិត្យ និងសម្រេច អ្នកស្នើសុំត្រូវផ្តល់ឯកសារចាំបាច់ក្នុងទម្រង់ពេញលេញ និងត្រឹមត្រូវសម្រាប់ការស្នើសុំដែលពាក់ព័ន្ធ។ ឯកសារខាងក្រោមនេះ គឺជាឯកសារតម្រូវចាំបាច់សម្រាប់ពាក្យសុំប្រកាសបង្កើត ឬការចុះបញ្ជីផ្សេងៗស្របតាមប្រកាសនេះ។ អ្នកស្នើសុំអាចផ្តល់ឯកសារបន្ថែមផ្សេងទៀតតាមករណីចាំបាច់ ប៉ុន្តែពុំមែនជាការតម្រូវឡើយ។

ក- ឯកសារតម្រូវសម្រាប់ការស្នើសុំប្រកាសបង្កើតរោងចក្រ រួមមាន ៖

១- ពាក្យស្នើសុំបង្កើតរោងចក្រ

២- លិខិតឯកភាពជាគោលការណ៍ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ប្រសិនបើមាន)

៣- លិខិតឯកភាពលើទីតាំងពីអាជ្ញាធរដែនដី ឬកិច្ចសន្យាជួលទីតាំង

៤- ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនទ្រព្យ

៥- លិខិតចុះបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈ

៦- សៀវភៅសិក្សាគម្រោងសមិទ្ធិលទ្ធភាព

៧- ប្លង់បង្ហាញទីតាំង ប្លង់គ្រឿងចក្រ គ្រឿងម៉ាស៊ីន

៨- លិខិតស្នើសុំដាក់ឈ្មោះរោងចក្រ

៩- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន និងរូបថត (៤x៦) ចំនួន ០៣សន្លឹក

ខ- ឯកសារតម្រូវសម្រាប់ការស្នើសុំប្រកាសបង្កើតសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម រួមមាន ៖

១- ពាក្យស្នើសុំប្រកាសបង្កើត

២- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែន និងរូបថត (៤x៦) ចំនួន ០៣សន្លឹក

៣- ប្លង់ និងគំនូសបំព្រួញខ្សែសង្វាក់ផលិតកម្ម

៤- លិខិតអង្កេតសុវិជាន-អសុវិជានបញ្ជាក់ដោយអាជ្ញាធរឃុំ/សង្កាត់

៥- លិខិតប្រគល់សិទ្ធិកាន់កាប់ឯកសារស្នើសុំ (បើមាន)

ឯកសារផ្សេងៗ

- ស្លាកសញ្ញាផលិតផល (បើមាន)
- កិច្ចសន្យាជួលទីតាំង (បើជួលទីតាំង)
- ផែនការការពារផលប៉ះពាល់បរិស្ថាន(បើចាំបាច់)

គ- ឯកសារតម្រូវសម្រាប់ស្នើសុំចុះបញ្ជីសិប្បកម្ម រួមមាន ៖

១- ពាក្យស្នើសុំចុះបញ្ជី

២- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនថតចម្លង និងរូបថត (៤x៦) ចំនួន ០៣សន្លឹក

ឃ- ឯកសារតម្រូវសម្រាប់ស្នើសុំចុះបញ្ជីរោងចក្រ សហគ្រាសធុនតូចនិងមធ្យម ដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចក្រសួងឧស្សាហកម្ម និងសិប្បកម្ម រួមមាន ៖

១- ពាក្យស្នើសុំចុះបញ្ជី

២- លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ផ្សេងៗថតចម្លងរបស់សមត្ថកិច្ចគ្រប់គ្រងផ្ទាល់

៣- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនថតចម្លង និងរូបថត (៤x៦) ចំនួន ០៣សន្លឹក



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៤៤
អ៊ីម៉ែល: mih.smcabinet@gmail.com

សម្រាប់សហគ្រាសកម្មន្តសាលមានបទដ្ឋានបច្ចេកទេសខ្ពស់ ៖

ឯកសារបន្ថែម ១ (មួយ)ច្បាប់ តាមការកំណត់ដោយឡែកដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីបញ្ជាក់ថា សហគ្រាសកម្មន្តសាលក្រោយការសាងសង់រួច អាចនឹងបំពេញតាមបទដ្ឋានបច្ចេកទេសខ្ពស់ ដែលអនុវត្តចំពោះសហគ្រាសប្រភេទនោះ។

**ប្រការ១១.- លេខសម្គាល់អចិន្ត្រៃយ៍**

មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ដែលទទួលខុសត្រូវធ្វើការចុះបញ្ជី ឬក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងផ្តល់លេខសម្គាល់អចិន្ត្រៃយ៍មួយដល់សហគ្រាសកម្មន្តសាលដែលបានស្នើសុំ។ លេខសម្គាល់នេះនឹងមានតែមួយគត់សម្រាប់សហគ្រាសមួយ ហើយអចិន្ត្រៃយ៍។

## ផ្នែកទី៣
## ការចុះបញ្ជីរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម

**ប្រការ១២.- រោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម មិនស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលត្រូវធ្វើការចុះបញ្ជី**

ម្ចាស់ ឬភ្នាក់ងារស្របច្បាប់របស់រោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដែលមិនស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវធ្វើការចុះបញ្ជីនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដូចមានចែងក្នុងមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ម្ចាស់ ឬភ្នាក់ងារនោះ មានកាតព្វកិច្ចដាក់ពាក្យស្នើសុំចុះបញ្ជីយ៉ាងយូរ ១៥ (ដប់ប្រាំ)ថ្ងៃ ក្រោយថ្ងៃដំណើរការ ឬទទួលបានការអនុញ្ញាតបង្កើតពីក្រសួងស្ថាប័នសាមីដែលមានសមត្ថកិច្ច។ ក្នុងករណីដែលបានបង្កើត និងដំណើរការរួចហើយ តែមិនទាន់បានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវមកចុះបញ្ជីក្រោយពីការជូនដំណឹងរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម យ៉ាងយូរ ១៥ (ដប់ប្រាំ)ថ្ងៃ។

**ប្រការ១៣.- សិប្បកម្មតម្រូវស្នើសុំចុះបញ្ជី**

ម្ចាស់ ឬភ្នាក់ងារស្របច្បាប់របស់សិប្បកម្មតម្រូវស្នើសុំចុះបញ្ជី មានសិទ្ធិ និងកាតព្វកិច្ចដាក់ពាក្យសុំចុះបញ្ជី ដើម្បីឲ្យសិប្បកម្មត្រូវបានចុះបញ្ជី។ មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ត្រូវទទួលយក និងធ្វើការចុះបញ្ជីរាល់ពាក្យស្នើសុំចុះបញ្ជី ដែលបានបំពេញត្រឹមត្រូវស្របតាមលក្ខខណ្ឌនៃប្រកាសនេះ។ ការចុះបញ្ជីមិនតម្រូវឲ្យធ្វើចំពោះសិប្បកម្មដែលតម្រូវសុំប្រកាសបង្កើតឡើយ។ នៅពេលដាក់ពាក្យសុំ អ្នកស្នើសុំត្រូវបង់ថ្លៃការដាក់ពាក្យសុំចុះបញ្ជីក្នុងចំនួនទឹកប្រាក់ដែលបានកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ត្រូវធ្វើការចុះបញ្ជី និងចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការ ដល់អ្នកស្នើសុំនៅក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលពាក្យស្នើសុំ។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៥៤
អ៊ីម៉ែល: mih.smcabinet@gmail.com

## ផ្នែកទី៤
## ការផ្តល់ប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម

### ប្រការ១៤.- លក្ខខណ្ឌតម្រូវនៃប្រកាសបង្កើត

ប្រកាសបង្កើត មិនត្រូវបានចេញជូនជាស្វ័យប្រវត្តិដល់អ្នកស្នើសុំនោះទេ ប៉ុន្តែនឹងផ្តល់ជូនតែក្នុងករណីអ្នកស្នើសុំបានបំពេញតាមលក្ខខណ្ឌតម្រូវជាធរមាននៃប្រកាស។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម អាចធ្វើបច្ចុប្បន្នភាព ឬកែលម្អលក្ខខណ្ឌតម្រូវនៃប្រកាសបង្កើតសម្រាប់សហគ្រាសកម្មន្តសាលផ្សេងៗ ដោយកំណត់បង្កើតលក្ខខណ្ឌតម្រូវអនុគ្រោះដល់សហគ្រាសកម្មន្តសាល និងធ្វើការកំណត់លក្ខខណ្ឌនៃប្រកាសអនុញ្ញាតដោយឡែកសម្រាប់សហគ្រាសកម្មន្តសាល ដែលជ្រើសរើសតាមការស្ម័គ្រចិត្តចង់បានការបញ្ជាក់ថា មានបទដ្ឋានបច្ចេកទេសខ្ពស់ស្របតាមប្រកាសនេះ។

លក្ខខណ្ឌតម្រូវអប្បបរមាសម្រាប់ការផ្តល់ប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម រួមមាន ៖

បទដ្ឋានស្តង់ដារបច្ចេកទេសអប្បបរមា ដើម្បីធានានូវសុវត្ថិភាពជាមូលដ្ឋាននៃសហគ្រាសកម្មន្តសាលសម្រាប់ការការពារបរិស្ថានសង្គម និងកម្មករ និង/ឬ

បទដ្ឋានស្តង់ដារអប្បបរមាសម្រាប់ប្រព័ន្ធគ្រប់គ្រង តាមដាន និងធានាគុណភាព សុវត្ថិភាពផលិតផល និងអនាម័យ។

### ប្រការ១៥.- គោលការណ៍ក្នុងការពិនិត្យសម្រេចចេញប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម អាចកំណត់នៅពេលក្រោយបន្ថែមទៀតនូវលក្ខខណ្ឌតម្រូវនៃប្រកាសបង្កើតដោយឡែកសម្រាប់ប្រភេទនីមួយៗនៃសហគ្រាសកម្មន្តសាល។ ក្នុងករណីពុំទាន់មានលក្ខខណ្ឌតម្រូវដោយឡែកនេះទេ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងអនុវត្តតាមគោលការណ៍ទូទៅ ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនលើការផ្តល់ ឬបដិសេធពាក្យស្នើសុំប្រកាសបង្កើត ដូចខាងក្រោម ៖

១- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជំរុញប្រសិទ្ធភាព តម្លាភាព និងភាពឆាប់រហ័សនៃដំណើរការពិនិត្យពាក្យស្នើសុំ ព្រមទាំងការធ្វើឲ្យសាមញ្ញនៃបែបបទសុំប្រកាសបង្កើត ដើម្បីលើកទឹកចិត្តដល់ការវិនិយោគឲ្យបានជាអតិបរមាក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មកម្មន្តសាល ប្រកបដោយការទទួលខុសត្រូវ។

២- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ខិតខំប្រឹងប្រែងឲ្យអស់ពីលទ្ធភាព ដើម្បីជួយដល់អ្នកស្នើសុំតាមការចាំបាច់ ដើម្បីរៀបចំពាក្យស្នើសុំ ដែលអាចទទួលយកបាន។

៣- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជំរុញការការពារភាពប្រកួតប្រជែងដោយស្មើភាព ហើយលើកលែងតែអ្នកស្នើសុំចង់បានការបញ្ជាក់ថា ជាសហគ្រាសកម្មន្តសាលមានស្តង់ដារខ្ពស់ នោះរាល់ពាក្យសុំប្រកាសបង្កើតនឹងត្រូវវិនិច្ឆ័យលើលទ្ធភាពរបស់អ្នកស្នើសុំ អនុលោមតាមស្តង់ដារអប្បបរមា ដែលជាទម្លាប់អនុវត្តទូទៅ និងបទដ្ឋានផលិតកម្មគំរូ ដែលអនុវត្តដោយសហគ្រាសកម្មន្តសាល ដែលកំពុងមានដំណើរការល្អ មានទំហំប្រហាក់ប្រហែលគ្នា និងផលិតផលដូចគ្នា។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ( ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧...
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៥៤
អ៊ីម៉ែល: mih.smcabinet@gmail.com

**ប្រការ១៦- សិប្បកម្មតម្រូវសុំប្រកាសបង្កើត**

សិប្បកម្មទាំងអស់ ដែលផលិត ឬនឹងផលិតផលិតផល ក្នុងបរិមាណអប្បបរមាដូចដែលបានកំណត់ខាងក្រោមនេះ ត្រូវធ្វើការស្នើសុំប្រកាសបង្កើតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមុន មុនពេលបង្កើត និងចាប់ផ្ដើមដំណើរការ។ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម អាចធ្វើបច្ចុប្បន្នភាព និងកែប្រែបញ្ជីប្រភេទសិប្បកម្ម ដែលតម្រូវសុំប្រកាសបង្កើតនៅក្នុងប្រកាសនេះ ដោយផ្សព្វផ្សាយការផ្លាស់ប្ដូរនេះ នៅក្នុងសេចក្ដីជូនដំណឹងរបស់ក្រសួង។ សិប្បកម្មផលិតផលិតផល ដែលតម្រូវឲ្យសុំប្រកាសបង្កើតពីក្រសួង មានដូចជា ៖

១- ស្បៀងអាហារ និងភេសជ្ជៈ
- ក- កែច្នៃអាហារ (លើសពី ២៥០ តោន ក្នុង ១ ឆ្នាំ)
- ខ- ទឹកកក និងទឹកបរិសុទ្ធ (លើសពី ១ តោន ក្នុង ១ ឆ្នាំ)
- គ- ទឹកក្រូច ទឹកផ្លែឈើ ទឹកស៊ីរ៉ូ សូដា... (គ្រប់ទំហំ)
- ឃ- ផលិត និងកែច្នៃស្រា (គ្រប់ទំហំ)
- ង- ផលិត និងកែច្នៃស្រាបៀរ (គ្រប់ទំហំ)
- ច- ទឹកស៊ីអ៊ីវ ទឹកសៀង ទឹកម្ទេស ទឹកប៉េងប៉ោះ... (គ្រប់ទំហំ)
- ឆ- ទឹកត្រី (លើសពី៥០០.០០០លីត្រក្នុង ១ឆ្នាំ)
- ជ- ប្រព្រឹត្តិកម្មសម្អាតទឹកផ្គត់ផ្គង់ និងចែកចាយ (គ្រប់ទំហំ)
- ឈ- ប្រេងឆា (គ្រប់ទំហំ)
- ញ- នំប៉័ង និងនំផ្អែម (គ្រប់ទំហំ)

២- វាយនភណ្ឌ សម្លៀកបំពាក់ និងផលិតផលអំពីស្បែក
- ក- ផលិត និងកែច្នៃស្បែក (គ្រប់ទំហំ)
- ខ- ការប្រេពណីខ្មែរ (ហៅថា ការស្បែកគោក្របី) (គ្រប់ទំហំ)

៣- ផលិតកម្មក្រដាស
- ក- ម្សៅក្រដាស ក្រដាស និងបោះពុម្ព (គ្រប់ទំហំ)

៤- ផលិតផលគីមី
- ក- ផលិតផលគីមីសរីរាង្គ អសរីរាង្គ (គ្រប់ទំហំ)
- ខ- ជីគីមី និងថ្នាំសម្លាប់សត្វល្អិត (គ្រប់ទំហំ)
- គ- ថ្នាំពណ៌ វ៉ែកនី និងថ្នាំពណ៌ប្រពៃណីខ្មែរ (ហៅថា ខ្មុកម្រ័ក្រ) (គ្រប់ទំហំ)
- ឃ- សាប៊ូ ទឹកអប់ និងផលិតផលប្រើប្រាស់លើរាងកាយផ្សេងទៀត (គ្រប់ទំហំ)
- ង- ផលិតផលប្លាស្ទិច និងកង់កៅស៊ូ (គ្រប់ទំហំ)
- ច- អាគុយ និងថ្មពិល (គ្រប់ទំហំ)
- ឆ- ជ័រឈើសំយោគ និងបង្កក (គ្រប់ទំហំ)
- ជ- ផលិតផលឧស្ម័ន និងថ្មស្កុយ (គ្រប់ទំហំ)
- ឈ- ប្រេងម៉ាស៊ូត និងប្រេងឥន្ធនៈផ្សេងៗ (គ្រប់ទំហំ)



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៨៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៥៤
អ៊ីម៉ែល: mih.smcabinet@gmail.com

## ប្រការ១៧.- ឆន្ទានុសិទ្ធិរបស់ក្រសួង ក្នុងការពិនិត្យសម្រេចលើពាក្យសុំប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម

ក្នុងរយៈពេល៤(បួន)ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលពាក្យស្នើសុំប្រកាសបង្កើតត្រូវបានទទួល អង្គភាពជំនាញរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មដែលមានសមត្ថកិច្ច ត្រូវពិនិត្យវាយតម្លៃលើលក្ខណៈសម្បត្តិរបស់គម្រោងស្នើសុំបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម តាមឯកសារចាំបាច់ ហើយរៀបចំ កំណត់បង្ហាញជាលាយលក្ខណ៍អក្សរជូនរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពិនិត្យ និងសម្រេចលើការស្នើសុំ។ អាស្រ័យឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការពិនិត្យ និងសម្រេចលើសំណើសុំបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ក្រសួងអាចជ្រើសរើសអនុវត្តជម្រើស ដូចតទៅ ៖

**ជម្រើសទី១ ៖**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពិនិត្យវាយតម្លៃសំណើសុំប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដោយផ្អែកលើការផ្តល់យោបល់ឯកភាពរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់។ ប៉ុន្តែការសម្រេចផ្តល់ការអនុញ្ញាត ឬមិនផ្តល់ការអនុញ្ញាតតាមការស្នើសុំ គឺជាឆន្ទានុសិទ្ធិរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មតែមួយគត់ ដោយផ្អែកលើលក្ខខណ្ឌតម្រូវបច្ចេកទេសចាំបាច់នានា សម្រាប់ការបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដែលបានកំណត់ និងផ្សព្វផ្សាយ។ ក្នុងន័យនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម អាចជ្រើសរើសធ្វើការសម្រេចលើពាក្យស្នើសុំ ដោយមិនចាំបាច់រង់ចាំការផ្តល់យោបល់ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ឬការវាយតម្លៃផលប៉ះពាល់ និងការការពារបរិស្ថានពីក្រសួងបរិស្ថាននោះទេ។ តាមឆន្ទានុសិទ្ធិរបស់ខ្លួន ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សម្រេចផ្តល់ប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ជូនតាមសំណើសុំ ប៉ុន្តែអាចកំណត់លក្ខខណ្ឌតម្រូវបន្ថែម មុនពេលផ្តល់វិញ្ញាបនបត្រអនុញ្ញាតដំណើរការ ដោយតម្រូវឱ្យអ្នកស្នើសុំផ្តល់ការបញ្ជាក់ពីការបានទទួលការយល់ព្រមលើទីតាំងពីអាជ្ញាធរមូលដ្ឋាន លិខិតអនុញ្ញាតផ្សេងៗពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ឬលិខិតឯកភាពពីក្រសួងបរិស្ថានចំពោះបញ្ហាពាក់ព័ន្ធនឹងផលប៉ះពាល់ និងការការពារបរិស្ថាន។

**ជម្រើសទី២ ៖**

មុនពេលក្រសួងឧស្សាហកម្ម និងសិប្បកម្ម សម្រេចចេញប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម អ្នកស្នើសុំ ត្រូវផ្តល់ជូនក្រសួងនូវការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអាជ្ញាធរមូលដ្ឋាន អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗ ឬក្រសួងបរិស្ថានតាមករណីចាំបាច់នីមួយៗ។ ដើម្បីទទួលបានប្រកាសបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម អ្នកស្នើសុំអាចមិនចាំបាច់បង្ហាញកម្មសិទ្ធិ ឬសិទ្ធិស្របច្បាប់របស់ខ្លួនក្នុងការប្រើប្រាស់ដីទីតាំង ដែលនឹងត្រូវសាងសង់ឡើយ។ ការកំណត់ពីតម្រូវការលិខិតឯកភាពពីស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗ គឺជាសិទ្ធិសម្រេចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយយោងតាមតម្រូវការចាំបាច់របស់ខ្លួន។

## ប្រការ១៨.- ការចាប់ផ្តើមដំណើរការរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម វិញ្ញាបនបត្រអនុញ្ញាតដំណើរការ

ក្រោយពេលរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ត្រូវបានសាងសង់បញ្ចប់ ឬស្ទើរតែបានបញ្ចប់ទាំងស្រុងរួចហើយ ម្ចាស់សហគ្រាសកម្មន្តសាលដែលទទួលបានប្រកាសបង្កើត ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការ ដូចមានចែងក្នុងប្រការ៦។ ពាក្យស្នើសុំត្រូវបញ្ជូនមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៩៤
អ៊ីមែល: mih.smcabinet@gmail.com

ដើម្បីពិនិត្យ និងសម្រេចចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការ មុនពេលសហគ្រាសកម្មន្តសាលចាប់ផ្តើមដំណើរការផលិតកម្មរបស់ខ្លួន។

ក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងចាត់មន្ត្រីរបស់ខ្លួនចុះធ្វើការត្រួតពិនិត្យបញ្ជាក់លើភាពអនុលោមត្រឹមត្រូវនៃការសាងសង់រោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ស្របតាមគំនូសប្លង់ ដែលបានស្នើសុំក្នុងប្រកាសបង្កើត និងលក្ខខណ្ឌតម្រូវផ្សេងៗ ដែលក្រសួងបានកំណត់។

ក្រសួងនឹងផ្តល់វិញ្ញាបនបត្រអនុញ្ញាតដំណើរការយ៉ាងយូរក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលពាក្យស្នើសុំរបស់ម្ចាស់សហគ្រាសកម្មន្តសាល ក្នុងករណីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានបញ្ជាក់ថា សហគ្រាសកម្មន្តសាលត្រូវបានសាងសង់ និងបំពេញបានត្រឹមត្រូវស្របតាមលក្ខខណ្ឌតម្រូវនានា។

ក្នុងករណីក្រសួងឧស្សាហកម្ម និងសិប្បកម្ម កំណត់ថា សហគ្រាសកម្មន្តសាលមានភាពខុសឆ្គងបច្ចេកទេសធ្ងន់ធ្ងរពីគំនូសប្លង់ ដែលបានស្នើសុំក្នុងប្រកាសបង្កើត ឬមិនអនុលោមតាមលក្ខខណ្ឌតម្រូវនានា ដែលក្រសួងបានកំណត់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងទំនាក់ទំនងម្ចាស់សហគ្រាសកម្មន្តសាលក្នុងរយៈពេលយ៉ាងយូរ ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការ ដើម្បីផ្តល់ជូនជាលាយលក្ខណ៍អក្សរនូវអនុសាសន៍ផ្សេងៗអំពីវិធានការនានា ដែលតម្រូវឲ្យម្ចាស់សហគ្រាសកម្មន្តសាលធ្វើការកែតម្រូវ ដើម្បីឲ្យមានភាពអនុលោមត្រឹមត្រូវ។ ក្រសួងនឹងមិនតម្រូវឲ្យម្ចាស់សហគ្រាសកម្មន្តសាលចាត់វិធានការណាផ្សេងទៀតក្រៅពីវិធានការកែតម្រូវ ដែលចែងជាលាយលក្ខណ៍អក្សរខាងលើឡើយ។ ក្រោយពីការអនុវត្តបញ្ចប់នូវវិធានការកែតម្រូវនានាដែលបានកំណត់ដោយក្រសួង ម្ចាស់សហគ្រាសកម្មន្តសាល ត្រូវដាក់ជូនក្រសួងត្រួតពិនិត្យនូវភស្តុតាង និងលទ្ធផលនៃវិធានការដែលបានអនុវត្ត និងស្នើសុំជាថ្មីនូវវិញ្ញាបនបត្រអនុញ្ញាតដំណើរការ។

## ផ្នែកទី៥
## លិខិតអនុញ្ញាតស្ម័គ្រចិត្តសម្រាប់សហគ្រាសកម្មន្តសាលមានស្តង់ដារខ្ពស់

**ប្រការ១៩.-**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងកំណត់ចេញការផ្សព្វផ្សាយអំពីលក្ខខណ្ឌតម្រូវនៃប្រកាស បញ្ជាក់សម្រាប់ការបង្កើតសហគ្រាសកម្មន្តសាលមានស្តង់ដារខ្ពស់ តាមការស្នើសុំរបស់ម្ចាស់សហគ្រាសកម្មន្តសាល ដែលមានបំណងចង់ទទួលបានការបញ្ជាក់ថា សហគ្រាសរបស់ខ្លួនជាសហគ្រាសកម្មន្តសាល ដែលមានស្តង់ដារខ្ពស់។ ការបញ្ជាក់សហគ្រាសមានស្តង់ដារខ្ពស់ គឺជាការផ្តល់កិត្តិយសពិសេសដល់សហគ្រាសកម្មន្តសាល ដើម្បីជួយ ៖

- កសាងទំនុកចិត្តលើផលិតផល ផលិតដោយសហគ្រាសនេះ
- បង្កើនលទ្ធភាពចូលក្នុងទីផ្សារនាំចេញជាមួយនឹងបទដ្ឋានត្រួតពិនិត្យគុណភាពតឹងតែងជាងបទដ្ឋាននានា ដែលត្រូវបានតម្រូវជាទូទៅនៅក្នុងប្រទេស
- ជំរុញលើកទឹកចិត្តដល់ការកែលម្អនៃសហគ្រាសកម្មន្តសាលក្នុងស្រុក ដើម្បីឈានទៅរកការប្រកាសទទួលស្គាល់ជាសហគ្រាសកម្មន្តសាល ដែលមានចំណាត់ថ្នាក់អាចប្រកួតប្រជែងជាសកល និងមានស្តង់ដារខ្ពស់។
- ផ្តោតលើគោលដៅនៃកិច្ចខិតខំប្រឹងប្រែងលើកស្ទួយការនាំចេញ តាមរយៈការជួយគាំទ្រសហគ្រាស



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៩៤
អ៊ីមែល: mih.smcabinet@gmail.com

ក្នុងស្រុកដែលស្ម័គ្រចិត្តស្នើសុំឲ្យមានការធ្វើអធិការកិច្ច ការត្រួតពិនិត្យ និងអនុវត្តតឹងរឹង តាមទម្លាប់អនុវត្តទូទៅ និងបទដ្ឋានស្តង់ដារអន្តរជាតិ។

- ជំរុញលើកទឹកចិត្តសហគ្រាសកម្មន្តសាល ដែលអនុវត្តឧស្សាហកម្មបៃតង និងបរិយាប័ន្ន។

ប្រកាសបញ្ជាក់សហគ្រាសកម្មន្តសាលមានស្តង់ដារខ្ពស់ ពុំមែនជាលក្ខខណ្ឌតម្រូវសម្រាប់សហគ្រាសកម្មន្តសាលណាមួយ មុនចេញប្រកាសបង្កើត ឬវិញ្ញាបនបត្រអនុញ្ញាតដំណើរការទេ។ ការបញ្ជាក់នេះ ត្រូវធ្វើតាមយន្តការស្ម័គ្រចិត្តចំពោះសហគ្រាស ដែលមានបំណងចង់បានការបញ្ជាក់នោះតែប៉ុណ្ណោះ។

## ជំពូកទី៦
## បទប្បញ្ញត្តិផ្សេងៗ និងអវសានប្បញ្ញត្តិ

### ប្រការ២០.- ទុនសមមូល

ទុនសមមូលរបស់សហគ្រាសកម្មន្តសាល ដែលបានស្នើសុំបង្កើត នឹងត្រូវបានកំណត់ជាដំបូង ដោយសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយម្ចាស់សហគ្រាសកម្មន្តសាល នៅក្នុងបែបបទស្នើសុំ។ ទុនសមមូលអប្បបរមា ដែលកំណត់សម្រាប់សហគ្រាសកម្មន្តសាល ដូចមានចែងនៅក្នុងប្រការ៤ ត្រូវកំណត់តាមតម្លៃដុល្លារអាមេរិកទៅតាមអត្រាប្តូរប្រាក់ ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

### ប្រការ២១.- ភាពអចិន្ត្រៃយ៍នៃប្រកាសបង្កើត និងលិខិតចុះបញ្ជី

ប្រកាសបង្កើត និងលិខិតចុះបញ្ជីទាំងអស់ ដែលផ្តល់ស្របតាមបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវមានសុពលភាពជាអចិន្ត្រៃយ៍ ក្នុងករណីដែលម្ចាស់សហគ្រាសកម្មន្តសាលអនុវត្តបានត្រឹមត្រូវ និងខ្ជាប់ខ្ជួននូវកាតព្វកិច្ច ៖

១- ផ្តល់ទិន្នន័យ និងរបាយការណ៍ត្រឹមត្រូវ ទៀងទាត់មកក្រសួងតាមការតម្រូវ និងបង់កម្រៃសេវាផ្សេងៗ ដែលត្រូវបានតម្រូវក្នុងប្រកាសរបស់ក្រសួង ដែលចែងអំពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រព្រឹត្តទៅ និងកិច្ចដំណើរការរបស់សហគ្រាសកម្មន្តសាល។

២- កិច្ចដំណើរការសហគ្រាសកម្មន្តសាល ត្រូវអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ សេវា និងច្បាប់ការពារបរិស្ថាន ព្រមទាំងច្បាប់ ឬបទបញ្ញាជាធរមានផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល។

៣- បានសាងសង់សហគ្រាសកម្មន្តសាល ស្របតាមលក្ខខណ្ឌតម្រូវជាក់លាក់នៃប្រកាសបង្កើត និងមានវិញ្ញាបនបត្រអនុញ្ញាតដំណើរការកំពុងមានសុពលភាព។

### ប្រការ២២.-

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងចេញប្រកាសដោយឡែកមួយទៀត សម្រាប់កំណត់ពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រព្រឹត្តទៅ និងកិច្ចដំណើរការរបស់សហគ្រាសកម្មន្តសាល។

### ប្រការ២៣.-

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម អនុវត្តការផ្ទេរមុខងារជូនរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបង្កើតរោងចក្រសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ក្នុងកម្រិតទុនជាក់លាក់ក្នុងលក្ខខណ្ឌជាកំណត់ ក្រោយពីបានសម្របសម្រួលនៃការផ្ទេរមុខងារ ពីគណៈកម្មាធិការជាតិអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ដោយ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៥៤
អ៊ីម៉ែល: mih.smcabinet@gmail.com

ប្រគល់ ឬប្រតិភូកម្មនូវមុខងារនោះ។ មន្ទីរឧស្សាហកម្ម និងសិប្បកម្ម គឺជាយន្តការសេនាធិការឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តនូវនីតិវិធី បែបបទ ការពិនិត្យលក្ខណៈបច្ចេកទេស ដើម្បីចេញដីកា ឬសេចក្តីសម្រេច ស្តីពីការបង្កើតរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ជូនអ្នកស្នើសុំ ស្របតាមមាត្រា១២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**ប្រការ២៤.- អវសានប្បញ្ញត្តិ**

ប្រកាសលេខ ៦០៧ ឧរថ អឧ.ប្រក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីនីតិវិធី និងបែបបទស្នើសុំបង្កើតរោងចក្រ-សិប្បកម្ម របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៥.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល គ្រប់អង្គភាពក្រោមឱវាទក្រសួង ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលារាជធានី ខេត្ត
- ដូចប្រការ២៥
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៥៤
អ៊ីមែល: mih.smcabinet@gmail.com